## ជំពូកទី៧: ផែនការគ្រប់គ្រងបរិស្ថាន_តម្រូវការស្ថាប័ន និងការពិនិត្យ-តាមដាន-វាយតំលៃបរិស្ថាន

**១៣៦.** យោងតាមវិធានការគ្រប់គ្រងដូចមាននៅក្នុងរបាយការណ៍វាយតំលៃអំពីហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង និងផែនការគ្រប់គ្រងបរិស្ថាន សំរាប់គំរោងស្រាវជ្រាវនឹងធ្វើអាជីវកម្មរ៉ែមាស ម្ចាស់គំរោងជាអ្នកទទួលខុសត្រូវសំខាន់ក្នុងការគ្រប់គ្រងបរិស្ថានរបស់គំរោងនេះ ចំណែកឯក្រសួងបរិស្ថាន និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងអាជ្ញាធរខេត្ត ជាអ្នកពិនិត្យការអនុវត្តន៍របស់ម្ចាស់គំរោង។

**១៣៧.** យោងលើកិរិតនៃផលប៉ះពាល់បង្កឡើងដោយសកម្មភាពអភិវឌ្ឍន៍ បង្ហាញថាគំរោងនេះតម្រូវឱ្យមានការចូលរួមពីស្ថាប័ន និងការត្រួតពិនិត្យបរិស្ថានច្រើន ព្រោះហេតុប៉ះពាល់អវិជ្ជមានអាចមានសភាពធ្ងន់ធ្ងរ ប្រសិនបើម្ចាស់គំរោង មិនយកចិត្តទុកដាក់ចំពោះបញ្ហាបរិស្ថាន។ ដូច្នេះ ក្រៅពីអ្នកសម្របសម្រួលបរិស្ថានរបស់ក្រុមហ៊ុន (Local Environmental Coordinator) និងស្ថាប័នជំនាញ (មានក្រសួងបរិស្ថាន ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) គម្រោងនេះចាំបាច់តម្រូវឱ្យមានស្ថាប័នត្រួតពិនិត្យឯករាជ្យ (Independent Monitoring Organization) ដើម្បីត្រួតពិនិត្យការអនុវត្តន៍។ ក្រុមហ៊ុនខ្លួនឯងមានតួនាទីទទួលខុសត្រូវស្នូលក្នុងការគ្រប់គ្រងបរិស្ថាន របស់គំរោងដោយផ្អែកលើវិធានការណ៍គ្រប់គ្រងបរិស្ថានដូចបានកំណត់នៅក្នុងផែនការគ្រប់គ្រងបរិស្ថាន របស់របាយការណ៍ IESIA។ ក្នុងបរិបទនេះ ដើម្បីធានាបានថា **ក្រុមហ៊ុន** DELCOM (KAMPUCHEA) PTE.LTD. ប្រតិបត្តិតាមវិធានការណ៍នៃការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង ដូចកំណត់នៅក្នុងតារាងទី ៧-១ និង៧-៣ បានត្រឹមត្រូវនោះ ក្រសួងបរិស្ថាន (នាយកដ្ឋាន EIA) និងក្រុមការងារចំរុះអន្តរៈក្រសួង ត្រូវចុះពិនិត្យ និងវាយតំលៃដំណើរប្រតិបត្តិរបស់ក្រុមហ៊ុន ទៅតាមកម្មវិធីដូចមានកំណត់នៅក្នុងតារាង ៧-៣ ដោយផ្ទាល់។

Draft

## តារាង ៧-១: សង្ខេបវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តំលៃប៉ាន់ស្មាន |
| --- | --- | --- | --- | --- |
| **ដំណាក់កាលស្រាវជ្រាវរុករករ៉ែ - ការធ្វើផែនការ** | | | | |
| ការធ្វើផែនការ | បទដ្ឋានសម្រាប់ការធ្វើផែនការស្រាវជ្រាវ និងធ្វើអាជីវកម្មរ៉ែ | • កំណត់អំពីចង្វាក់ និងរបៀបនៃប្រតិបត្តិការចំរាញ់ (ទាញ) យករ៉ែ និងវិធីសាស្ត្រក្នុងការបិទរណ្តៅរ៉ែ និងការជួសជុលបរិស្ថានឡើងវិញ។ នៅក្នុងការរៀបចំផែនការចាំបាច់ត្រូវពិចារណាទៅលើបញ្ហាមួយចំនួនដូចខាងក្រោម:<br>(១) ការឈូសឆាយដីស្រទាប់លើការរក្សា និងគ្រប់គ្រងអាចម៍ដីនេះអោយបានត្រឹមត្រូវសម្រាប់ប្រើនៅពេលបិទរណ្តៅរ៉ែ។<br>(២) រៀបចំទីស្នាក់ការ ផ្ទះសម្រាប់បុគ្គលិកកម្មករស្នាក់នៅ រោងជាង សួនច្បារ និងទីលានកីឡា។<br>(៣) កំណត់ទីតាំងសម្រាប់រក្សា និងការពារកាកសំណល់ (អាចម៍) រ៉ែ ជាពិសេសប្រសិនបើកាកសំណល់ទាំងនោះមានសារធាតុ Sulfur ដែលអាចធ្វើអោយមានជា AMD បាន។<br>(៤) ប្រព័ន្ធស្រះដើម្បីធ្វើទឹកអោយរង និងលទ្ធភាពរក្សាទឹកនៅពេលមានភ្លៀង។<br>(៥) វិធីសាស្ត្រយករ៉ែធ្វើយ៉ាងណា ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការបិទរណ្តៅ<br>(៦) វិធីសាស្ត្រសម្រាប់ធ្វើការបិទរណ្តៅ និងការជួសជុលបរិស្ថានឡើងវិញ (ការកែប្រែដី និងការដាំឈើ)។<br>(៧) វិធីសាស្ត្រដាក់ម៉ាស៊ីនផ្ទុះដែលអាចកាត់បន្ថយសម្លេង និងរំញ័រ។ | ម្ចាស់ក្រុមហ៊ុន | ៣៥០០០ |

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|
| ដំណាក់កាលស្រាវជ្រាវរុករករ៉ែ (ត) | | | | |
| ការធ្វើផែនការ | បទដ្ឋានសម្រាប់ការធ្វើផែនការស្រាវជ្រាវ និងធ្វើអាជីវកម្មរ៉ែ | (១) ការការពារជំងឺគ្រុនឈាម: ប្រសិនបើគ្មានការគ្រប់គ្រងកន្លែងដែលមូសរស់នៅអោយបានជិតដល់ទេអាចនឹងធ្វើអោយកើតជំងឺគ្រុនឈាមបាន។ អនុសាសន៍សំខាន់ៗសំរាប់ការការពារ និងការកាត់បន្ថយនូវការកើតឡើងរបស់ជំងឺមានដូចជា: (ក) សំអាតកន្លែងដែលមូសរស់នៅ (ទាំងក្នុងលក្ខខ័ណ្ឌធម្មជាតិ និងសិប្បនិម្មិត) ជាកន្លែងដែលមានទឹក បង្កលក្ខណ:សមស្របដល់ការបង្កាត់ពូជមូសដែលមាននៅជុំវិញនោះ (ខ) អប់រំកម្មករ និងសហគមន៍មូលដ្ឋាន អោយបំផ្លាញទីកន្លែងជំរករបស់មូស (គ) ធ្វើការអង្កេត និងកំណត់អំពីដង់ស៊ីតេរបស់មូសដែលចំលងមេរោគ និង (ឃ) បាញ់ថ្នាំសំលាប់មូសជាប្រចាំ ជាពិសេសនៅពេលដែលមានមូសច្រើន។<br>(២) វិធានការណ៍ការគ្រប់គ្រងការរាតត្បាត: វិធានការណ៍សំខាន់ៗសម្រាប់គ្រប់គ្រងការរាតត្បាតរបស់ជំងឺឆ្លងមានដូចជា: (ក) ត្រូវបំបែកអ្នកជំងឺអោយនៅកន្លែងផ្សេង និងផ្តល់ការព្យាបាលជាពិសេសទៅតាមយថាប្រភេទនៃជំងឺ (ខ) បាញ់ថ្នាំក្នុងបរិវេណរស់នៅចំងាយ ២០០ម ដើម្បីសម្លាប់មូសពេញវ័យ (គ) ស្វែងរក និងបំផ្លាញទីតាំងជំរកមូស (ឃ) ចាំបាច់ត្រូវប្រើថ្នាំសំលាប់ពងមូស ចំពោះទីកន្លែងដែលមានមូសច្រើន និង (ង) អប់រំដល់បុគ្គលិកកម្មករ និងសហគមន៍អំពីវិធានការណ៍គ្រប់គ្រងការរាតត្បាត។ | ម្ចាស់ក្រុមហ៊ុន | ១២០០ |

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|
| **ដំណាក់កាលស្រាវជ្រាវរុករករ៉ែ (ត)** | | | | |
| ការធ្វើផែនការ | បទដ្ឋានសម្រាប់ការធ្វើផែនការស្រាវជ្រាវ និងធ្វើអាជីវកម្មរ៉ែ | (៣) ការការពារជំងឺដែលបង្កឡើងដោយការប្រើប្រាស់ទឹកមិនស្អាត: ការកើតជំងឺគ្រុនពោះវៀន រាគមូល អាសន្នរោគ រលាកថ្លើម និងទឹកស៊ីជើងមានកំរិតខ្ពស់ ដោយសារការខ្វះអនាម័យ ការប្រើប្រាស់បង្គន់សាធារណៈមានកំរិតទាប ការផ្គត់ផ្គង់ទឹកស្អាតនៅមានកំរិត និងការខ្វះអនាម័យរបស់កម្មករ។ អនុសាសន៍មួយចំនួនដែលអនុវត្តសម្រាប់ការពារនូវការកើតនូវជំងឺខាងលើមាន: (ក) ក្រុមហ៊ុនត្រូវផ្តល់ទឹកស្អាតដល់កម្មករ។ ដោយហេតុថាទឹកអណ្តូងមានជាតិកំបោរច្រើនមិនអាចប្រើប្រាស់បាន បច្ចុប្បន្នក្រុមហ៊ុនបានជីកស្រះត្រងទឹកស្រទាប់លើ បន្ទាប់ពីច្រោះទឹកនេះអោយស្អាត ហើយយកទៅដាំអោយពុះទើបប្រើប្រាស់ (ខ) ត្រួតពិនិត្យជាប្រចាំអំពីគុណភាពរបស់ទឹក (វត្តមានរបស់បាក់តេរី សារធាតុគីមី និងពណ៌របស់ទឹក) (គ) ត្រូវធ្វើរោគវិនិច្ឆ័យ និងផ្តល់ការព្យាបាលអោយបានគ្រប់គ្រាន់ និងទាន់ពេលវេលា (ឃ) តាមដានរកប្រភពចំលង និងផ្តល់ការព្យាបាល (ង) ធានាអោយបាននូវសុវត្ថិភាព និងអនាម័យកាកសំណល់ និងការបោះចោលនូវសំណល់រឹងនៅក្នុងផ្ទះដែលសង់សំរាប់កម្មករ (ច) កែលំអការសម្អាតបរិស្ថាននៅក្នុងបរិវេណទីស្នាក់ការ និងទីកន្លែងរស់នៅ ដោយការសង់បង្គន់អនាម័យ និងកន្លែងសំរាប់ចោលសំណល់រឹង (ឆ) កែលំអអនាម័យបុគ្គល ជាពិសេសចំពោះអ្នករៀបចំអាហារ (ជ) ផ្តល់វ៉ាក់សាំងចំពោះបុគ្គលិក ឬកម្មករបរទេសដែលពុំមានអង់ទីករប្រឆាំងជំងឺគ្រុនពោះវៀន អាសន្នរោគ និងរលាកថ្លើម និង (ឈ) រាយការណ៍នឹងធ្វើការត្រួតពិនិត្យអំពីឧប្បទ្ទហេតុរបស់ជំងឺ។ | ម្ចាស់ក្រុមហ៊ុន | ៣៥០០ |

Draft

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|
| **ដំណាក់កាលស្រាវជ្រាវរុករករ៉ែ (ត)** | | | | |
| ការធ្វើផែនការ | បទដ្ឋានសម្រាប់ការធ្វើផែនការស្រាវជ្រាវ និងធ្វើអាជីវកម្មរ៉ែ | (៤) ការការពារជំងឺផ្លូវភេទ: ការការពារជំងឺផ្លូវភេទចំពោះកម្មករ និងសហគមន៍មូលដ្ឋានអាចធ្វើបានតាមរយៈ (ក) អប់រំបុគ្គលិក កម្មករអំពីគ្រោះថ្នាក់នៃការឆ្លងជំងឺអេដស៍ និងជំងឺផ្លូវភេទផ្សេងៗទៀតដូចជាការទប់ស្កាត់នូវទំនាក់ទំនង ជាមួយអ្នកដែលធ្វើអាជីវកម្មលើផ្លូវភេទ ការប្រើប្រាស់ស្រោមអនាម័យ ណែនាំអ្នកជំងឺអោយព្យាបាលជាមួយនឹងគ្រូពេទ្យដែលមានបទពិសោធន៍ និងមិនត្រូវព្យាបាលដោយខ្លួនឯង និង (ខ) រាយការណ៍អំពីអ្នកជំងឺ ស្វែងរកអ្នកចំលង និងត្រួតពិនិត្យករណីនៃការកើតមានរបស់ជំងឺ ដោយការិយាល័យសុខាភិបាលនៅក្នុងតំបន់។ ប្រសិទ្ធិភាពនៃកម្មវិធីការពារជំងឺផ្លូវភេទទាមទារឱ្យមានកិច្ចសហប្រតិបត្តិការរវាងក្រុមការងារសុខាភិបាល អាជ្ញាធរ សហគមន៍មូលដ្ឋាន និងក្រុមហ៊ុន។ | ម្ចាស់ក្រុមហ៊ុន | ៣៥០០ |

Draft

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|
| **ដំណាក់កាលស្រាវជ្រាវរុករករ៉ែ (ត)** | | | | |
| **ការធ្វើផែនការ** | **បទដ្ឋានសម្រាប់ការធ្វើផែនការស្រាវជ្រាវ និងធ្វើអាជីវកម្មរ៉ែ** | (៥) ការរៀបចំផ្ទះ និងសុខភាព: ការរៀបចំផ្ទះមិនបានត្រឹមត្រូវ (ខ្វះអនាម័យ មនុស្សច្រើនហួសកំរិត និងខ្យល់អាកាសអាប់អួរ) អាចនាំអោយមានការចំលងប៉ារ៉ាស៊ីត ជំងឺចំលងតាមខ្យល់ គ្រោះថ្នាក់ដោយការប៉ះទង្គិច និងស្ត្រេសជាដើម។ តែបញ្ហាទាំងនេះអាចកាត់បន្ថយតាមរយៈការអនុវត្តន៏នូវវិធានការណ៍មួយចំនួនដូចជា: (ក) ត្រូវរៀបចំប្លង់កសាងទីស្នាក់ស្នួលឱ្យបានត្រឹមត្រូវ (ខ) ត្រូវផ្តល់ផ្ទះដល់កម្មករទៅតាមលក្ខខ័ណ្ឌ: (គ) ទីតាំងផ្ទះចាំបាច់ត្រូវស្ថិតនៅផុតពីកំពស់ទឹកជំនន់ ស្ថិតនៅឆ្ងាយពីទីកន្លែងដែលអាចផ្តល់ភាពក្រខ្វក់និងកន្លែងដែលមានសត្វល្អិតច្រើន។ ផ្ទះកម្មករត្រូវមានសំណាញ់ការពារមូសនិងត្រូវមានពន្លឺ និងចរន្តខ្យល់គ្រប់គ្រាន់ (ផ្ទៃបន្ទប់ត្រូវបើកចំហយ៉ាងតិច១០ភាគរយ) (ឃ) លក្ខណ:អនាម័យ: ផ្តល់ទឹកស្អាតឱ្យបានគ្រប់គ្រាន់ជាមួយនឹងមធ្យោបាយសំរាប់ដុសលាងនិងងូតទឹក សង់បង្គន់អនាម័យ និងកន្លែងសំរាប់ចោលសំណល់រឹងត្រឹមត្រូវ និង (ង) ពិនិត្យអំពីលទ្ធភាពនៃការផ្តល់កន្លែងសំរាប់លំហែ (តារាងបាល់បោះ បាល់ទះ និងបាល់ទាត់) និងមណ្ឌលសុខភាព។ | ម្ចាស់ក្រុមហ៊ុន | ១២០០០០ |

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|
| **ដំណាក់កាលស្រាវជ្រាវរុករករ៉ែ (ត)** | | | | |
| | កំនើននៃគ្រោះថ្នាក់ក្នុងពេលធ្វើការក្នុងអណ្តូងរ៉ែ | • ដើម្បីទប់ស្កាត់នូវគ្រោះថ្នាក់ក្នុងពេលធ្វើការក្នុងអណ្តូងរ៉ែ ក្រុមហ៊ុនត្រូវ: (១) រៀបចំនិងអនុវត្តនូវគោលការណ៍សុវត្ថិភាពទៅតាមបទដ្ឋានការងារក្នុងអណ្តូងរ៉ែ (២) បំពាក់មួកការពារអោយដល់គ្រប់កម្មករ ដែលធ្វើការក្នុងអណ្តូងរ៉ែ ដើម្បីការពារក្បាលពីការធ្លាក់ថ្មដោយចៃដន្យ (៣) ផ្តល់មធ្យោបាយសំរាប់ព្យាបាលបន្ទាន់នៅក្នុងគ្លីនីករបស់ទីស្នាក់ការស្នូល (៤) រៀបចំវិធានការណ៍សំរាប់សង្គ្រោះបន្ទាន់ ដើម្បីបញ្ជូនអ្នករងគ្រោះឬអ្នកជំងឺធ្ងន់ធ្ងរទៅកាន់មន្ទីរពេទ្យ ។ | ម្ចាស់ក្រុមហ៊ុន | ២០០០ |
| | បាធីភ័យសុវត្ថិភាព | • ការរៀបចំផែនការសុខភាព និងសុវត្ថិភាពការងារ ការផ្តល់នូវការបណ្តុះបណ្តាលផ្សេងៗ និងការណែនាំដល់បុគ្គលិកកម្មករទាំងមុនពេលប្រគល់ភារកិច្ចផ្សេងៗ ។ | ម្ចាស់ក្រុមហ៊ុន | ២៥០០ |

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|
| **ដំណាក់កាលស្រាវជ្រាវរុករករ៉ែ (ត)** | | | | |
| **ការសាងសង់ទីស្នាក់ការមេ និងរោងចក្រកិនថ្មរ៉ែ កន្លែងកម្មករស្នាក់នៅ កន្លែងកិនរ៉ែ កន្លែងរែងរ៉ែ កន្លែងលាង និង ធ្វើ និស្សារណកម្មមាស ស្រះស្តុកទឹកសំរាប់លាងរ៉ែ សំរាប់ប្រើប្រាស់រៀបចំប្រព័ន្ធរក្សា និងការពារកាកសំណល់រ៉ែ និងផ្ទៃដីបំរុងសម្រាប់រក្សាកាកសំណល់រ៉ែ និងស្រះរក្សាទឹកស្អាត** | *បង្ករការហូរច្រោះដីមជ្ឈដ្ឋានជុំវិញ ដោយការឈូសសម្អាតគំរបព្រៃ (ទឹកភ្លៀង ឬទឹកស្រទាប់លើ)* | • ការឈូសឆាយគំរបព្រៃដើម្បីសាងសង់នេះ គឺចាំបាច់ត្រូវធ្វើឡើងដោយចៀសពុំរួចឡើយ ។ ហើយហេតុប៉ះពាល់ដែលកើតមានឡើងដោយសកម្មភាពទាំងនេះមិនបង្កជាបញ្ហាធ្ងន់ធ្ងរដល់បរិស្ថានឡើយ ហើយហេតុប៉ះពាល់ទាំងនេះអាចកាត់បន្ថយបានតាម: (១) កាកសំណល់ឈើធំ ៗ (គល់ សំបក ដើម និងមែក) ដែលកើតមាននៅក្នុងរយ:ពេលនៃការសាងសង់ត្រូវកាត់ទៅជាកំណាត់តូចៗ ហើយឈូសទៅគរនៅកន្លែងមួយសមស្រប (មិនត្រូវរុញអោយទៅកកស្ទះនឹងរុក្ខជាតិក្បែរៗនោះ ឬក៏នៅកន្លែងទីជំរាលនោះទេ ។ ពីព្រោះថាក្រៅពីអាចប្រើប្រាស់ជាឧសដុត វាអាចជួយការពារដី ហើយម៉្យាងទៀតក្រោយពេលពុកផុយវានឹងផ្តល់ជីដល់ដីទៀតផង (២) ត្រូវជ្រើសរើសកន្លែងគរឈើដោយប្រុងប្រយ័ត្ន ដើម្បីចៀសវាងកន្លែងដែលមានដំណុះរុក្ខជាតិក្រាស់ និងក្បែរផ្លូវទឹក ។ ការហូរច្រោះផ្ទៃខាងលើរបស់ដីកើតមានឡើងតិចតួច ចំពោះកន្លែងណាដែលសណ្ឋានដីមានលក្ខណ:រាបស្មើ ។ នៅជុំវិញកន្លែងគរឈើចាំបាច់ត្រូវមានតំបន់ក្រវ៉ាត់ដែលមានដុះរុក្ខជាតិក្រាស់ ដើម្បីទប់ស្កាត់ការហូរជ័រ និងសារធាតុពុលផ្សេងៗ ទៀតចេញពីឈើនៅពេលដែលមានភ្លៀងធ្លាក់ខ្លាំង ជ័រ និងកាកសំណល់ផ្សេងៗទៀតដែលកើតមានឡើងនៅពេលកាប់ឈើចាំបាច់ត្រូវយកចេញ និងចោលឱ្យបានត្រឹមត្រូវ និង (៣) ក្រោយពេលសាងសង់រួច (ទីស្នាក់ការស្នូល ផ្ទះបុគ្គលិក កម្មករ ផ្ទះបាយ រោងជាង បង្គន់អានាម័យ ផ្លូវនៅក្នុងបរិវេណទីធ្លាកីឡា...) ផ្ទៃដីដែលនៅសេសសល់ត្រូវរៀបចំដាំឈើឡើងវិញជាបន្ទាន់ ដោយមានការរៀបចំអោយទៅជាលក្ខណ:សួនច្បារ ឬច្បារដំណាំ (ពពួកបន្លែជាដើម) ធ្វើដូច្នេះគឺដើម្បីកាត់បន្ថយការហូរច្រោះដីពីទីកន្លែងនោះ ។ | ម្ចាស់ក្រុមហ៊ុន | ២០០០ |



Draft

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|
| **ដំណាក់កាលស្រាវជ្រាវរុករករ៉ែ (ត)** | | | | |
| **ការសាងសង់** | ***បង្ករការក្រខ្វក់ដល់មជ្ឈដ្ឋានជុំវិញ ដោយការឈូសសម្អាតរុក្ខជាតិដែលដុះអមសងខាងផ្លូវដែលមានស្រាប់*** | • ការឈូសសម្អាតរុក្ខជាតិដើម្បីធ្វើផ្លូវ ក្រៅពីការបាត់បង់គំរបព្រៃ ជានិច្ចជាកាលតែងតែមានការប៉ះពាល់ ឬខូចខាតដល់បរិស្ថានជុំវិញដោយចៀសមិនរួចឡើយ ។ ប៉ុន្តែហេតុប៉ះពាល់ទាំងនេះអាចកាត់បន្ថយបានតាម: (១) កាកសំណល់ឈើ (គល់ សំបក ដើម និងមែក) ដែលកើតមានពីការសាងសង់ផ្លូវត្រូវកាត់ទៅជាកំណាត់តូចៗ និងរាយនៅតាមដងផ្លូវ ប៉ុន្តែមិនត្រូវរុញអោយទៅកកស្ទះនឹងរុក្ខជាតិ ដែលមាននៅតាមដងផ្លូវ ឬក៏នៅកន្លែងទីជំរេលនេះទេ ។ ពីព្រោះថា ក្រៅពីការការពារដី កាកសំណល់ទាំងនេះនឹងពុកផុយ ហើយនឹងផ្តល់ជីដល់ដីទៀតផង (២) ការកំណត់នូវកន្លែងសំរាប់ដាក់លូមានសារៈសំខាន់ណាស់ ពីព្រោះការរំនោះទឹកចេញពីផ្នែកម្ខាង ទៅផ្នែកម្ខាងទៀតចំបាច់ត្រូវធ្លាក់ទៅលើកន្លែងដែលមានដីរឹង (៣) រក្សានូវមុំរបស់ផ្លូវទៅតាមលក្ខណៈវិស្វកម្មរបស់ផ្លូវ (មិនធំជាង១០ភាគរយចំពោះដីជ្រាយ និងមិនធំជាង១៤ភាគរយ ចំពោះដីរឹង) (៤) ត្រូវកាយចង្អូរនៅតាមដងផ្លូវ ហើយទ្រូងផ្លូវត្រូវមានរាងជាខ្នងអណ្តើក ដើម្បីអោយងាយហូរធ្លាក់ទៅចង្អូរ (៥) ចៀសវាងការឈូសឆាយគំរបព្រៃនៅក្នុងពេលកំពុងភ្លៀង ឬនៅក្នុងសណ្ឋានភាពសើម (៦) ខ្នងផ្លូវត្រូវក្រាលថ្មបាយក្រៀម ឬក៏កំទេចថ្ម (៧) ប្រើគ្រឿងចក្រអោយបានសមស្របដើម្បីកាត់បន្ថយហេតុប៉ះពាល់ពីការដាច់ដី (៨) ការដាក់លូអោយបានសមស្របតាមទីកន្លែង អាចនឹងកាត់បន្ថយនូវការប៉ះពាល់ទូទៅដល់សត្វដែលរស់នៅក្នុងទឹក (៩) ដើម្បីកាត់បន្ថយនូវការដែលអាចបង្កអោយមានភាពក្រខ្វក់ដល់ផ្លូវទឹក ការសាងសង់ផ្លូវទៅកាន់អណ្តូងរ៉ែត្រូវធ្វើនៅក្នុងរដូវប្រាំង និង (១០) ការពារតំបន់រណបរបស់អូរ និងស្ទឹង ។ | ម្ចាស់ក្រុមហ៊ុន | - |

Draft

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|
| **ការជីកយករ៉ែនិងដឹកជញ្ជូនរ៉ែទៅកាន់រោងចក្រ (ត)** | | | | |
| **ការដឹកជញ្ជូន** | **រំខានដល់មជ្ឈដ្ឋានជុំវិញ (សម្លេង រំញ័រ និងធូលី)** | • ហេតុផលប៉ះពាល់បណ្តាលមកពីការដឹកជញ្ជូនរ៉ែទៅកាន់រោងចក្រមានដូចជា: សម្លេង រំញ័រ ដោយការធ្វើចរាចរណ៍របស់ឡានដឹករ៉ែ និងការបង្កអោយមានធូលី ខ្សែឡានដឹករ៉ែទាំងនោះ។ តែផលប៉ះពាល់នេះមិនធ្ងន់ធ្ងរទេ ដោយសារតំបន់នោះមានស្រទាប់រុក្ខជាតិនៅតាមដងផ្លូវ ហើយម្យ៉ាងទៀតតំបន់នេះមានប្រជាជនរស់តិច។ ធូលីដែលបានហើរទៅទុំតាមស្លឹកឈើ ជាការរំខានដល់ការលទ្ធភាពស្រូបយកពន្លឺ និងប្រសិទ្ធិភាពនៃដំណើរការរស្មីសំយោគរបស់រុក្ខជាតិបៃតង។ បញ្ហាដែលបង្កចំពោះដំណុះរុក្ខជាតិអាចអូសបន្លាយរយៈពេល៦ខែ រហូតដល់មានភ្លៀង។ ប៉ុន្តែហេតុប៉ះពាល់នេះអាចកាត់បន្ថយបានតាមរយៈការក្រាលផ្លូវដោយគ្រួសក្រហម នឹងធ្វើការជ្រោមផ្លូវដោយការស្រោចទឹកជាប្រចាំ។ | ម្ចាស់ក្រុមហ៊ុន | ១២០០ |

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|
| **ការទាញយករ៉ែចេញពីថ្ម និងការចោលសំណល់ (អាចម៍) រ៉ែ** | | | | |
| ការលាងសម្អាតរ៉ែ | បង្ករអោយក្រខ្វក់ដល់មជ្ឈដ្ឋានជុំវិញ ជាពិសេសប្រព័ន្ធអូរ-ស្ទឹង និងខ្ទះអាចម៍ ដីដើម្បីលុបរណ្តៅរ៉ែ | • រ៉ែនៅតែមានលក្ខណៈក្រខ្វក់(លាយជាមួយនឹងដីនិងសម្រាមផ្សេងៗទៀត) មុននឹងកិនបំបែកជាបំណែកល្អិតៗ ត្រូវលាងសម្អាតជាមុនសិន ហើយទឹកដែលចាំបាច់ត្រូវលាងសម្អាតរ៉ែ គឺមានបរិមាណច្រើននឹងក្រខ្វក់ដោយសារធាតុក្រខ្វក់ផ្សេងៗ មានទាំងរូប និងគីមី ។ ប្រសិនបើបញ្ចេញទឹកនេះចោលភ្លាមទៅក្នុង ឬតាមប្រភពទឹកធម្មជាតិ (គន្លងទឹកហូរ ឬកូនអូរតូចៗដែលមានទឹក តែនៅក្នុងពេលមានភ្លៀងធ្លាក់ និងក្រោយពីភ្លៀងធ្លាក់រួចរយៈពេលខ្លី) នោះនឹងបង្កអោយមានហេតុប៉ះពាល់បរិស្ថានដោយការដុះដីនៅតាមទីទំនាប និងការបំពុលដោយសារធាតុគីមី ប្រសិនបើមានសម្ព័ន្ធគីមីសកម្មនៅលាយលំជាមួយនឹងរ៉ែក្នុងល័ក្ខខ័ណ្ឌធម្មជាតិ ។ ដើម្បីទប់ស្កាត់ ហេតុប៉ះពាល់ទាំងនេះក្រុមហ៊ុនត្រូវ:<br>**(១) *រៀបចំប្រព័ន្ធស្រះ (Sedimentation Systems) អោយត្រូវទៅតាមបទដ្ឋានបច្ចេកទេសសម្រាប់ការធ្វើអាជីវកម្មលើរ៉ែ ដូចមានបង្ហាញជូន ក្នុងជំពូកទី៦ ។*** ប្រព័ន្ធនេះ ត្រូវរៀបចំប្រកបដោយលក្ខណៈគ្រប់គ្រាន់ដើម្បីរក្សាទឹក (ទាំងបរិមាណ និងពេលវេលាសម្រាប់បង្ហាំងទឹក) សំណល់ទាំងនោះអោយរងបានល្អជាមុន (ឬមានពេលវេលាគ្រប់គ្រាន់សម្រាប់ការធ្វើ អុកស៊ីតកម្មទៅលើប្រភេទអំបិលរ៉ែមួយចំនួនដូចជា Thiosalt ជាដើម) មុននឹងបញ្ចេញចោល ។<br>**(២)** ដោយហេតុថាតំបន់នោះមានរដូវប្រាំងតិចជាងបួនខែ ពោលគឺជាតំបន់ដែលមានភ្លៀងធ្លាក់ច្រើន ដូច្នេះនៅក្នុងដំណាក់កាលនៃការធ្វើផែនការសម្រាប់រៀបចំប្រព័ន្ធ Sedimentation ក៏ត្រូវពិចារណាអំពីលទ្ធភាពរក្សាទឹកនៅពេលមានភ្លៀងផងដែរ (Buffer Capacity for the Rainy Season) ។ | ម្ចាស់ក្រុមហ៊ុន | ១៥០០០០ |

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|
| **ការទាញយករ៉ែចេញពីថ្ម និងការចោលសំណល់ (អាចម៍) រ៉ែ (ត)** | | | | |
| **ការកិនបំបែករ៉ែ** | **រំខានដល់មជ្ឈដ្ឋានជុំវិញ (សម្លេង និងធូលី)** | • ក្រោយពីលាងស្អាតហើយ ថ្មរ៉ែនោះត្រូវកិនបំបែកជាម្សៅ (១២៥មីក្រុង) ដោយម៉ាស៊ីនកិនរ៉ែបាន ៣០០០តោនក្នុង១ខែ ។ ហេតុប៉ះពាល់ដែលកើតឡើងដោយការកិនបំបែកថ្មគឺ សម្លេង និងបំភាយ ធូលី (ក្នុងនោះអាចមានទាំងសារធាតុគីមីផងដែរ) ។ តែហេតុប៉ះពាល់ទាំងនេះអាចកាត់បន្ថយបាន ដោយ:<br>(១) ត្រូវបំពាក់ឧបករណ៍ការពារត្រចៀក អោយដល់បុគ្គលិកកម្ម ដែលធ្វើការនៅកន្លែងកិនថ្ម ។<br>(២) ប្រើគំរប ឬផ្ទាំងអ្វីមួយទៅហ៊ុំព័ទ្ធបរិវេណកិនបំបែកថ្មដើម្បីទប់ស្កាត់ (កាត់បន្ថយ) ការបំភាយធូលីចេញ ។ | ម្ចាស់ក្រុមហ៊ុន | ១២០០ |
| **ការទាញយករ៉ែ និងការចោលកាកសំណល់រ៉ែ** | **បង្ករអោយក្រខ្វក់ដល់មជ្ឈដ្ឋានជុំវិញ ជាពិសេសប្រព័ន្ធស្ទឹង និងខូចអាចម៍ដីដើម្បីលុបរណ្តៅរ៉ែ** | • ***ក្រោយពីទាញយករ៉ែរួច កាកសំណល់រ៉ែទាំងនោះត្រូវដឹកយកទៅគរទុកនៅកន្លែងរាបស្មើ ហើយនៅឆ្ងាយពីប្រព័ន្ធស្ទឹង ។ កាកសំណល់ទាំងនេះត្រូវទុកប្រើនៅពេលបិទរណ្តៅរ៉ែដូចមានបង្ហាញជូននៅក្នុងជំពូកទី៦ ។***<br>• ប្រសិនបើកាកសំណល់រ៉ែទាំងនោះសម្បូរណ៍ទៅដោយសារធាតុ Sulfur ទឹកដែលហូរចេញមកដោយការជ្រាបនោះតែងមានលក្ខណៈអាស៊ីដខ្ពស់ ហើយអាចសម្បូរណ៍ទៅកំហាប់លោហៈធុនធ្ងន់ដែលអាចរលាយបាន ហៅកាត់ថា AMD (Acid Mine Drainage) ជាធម្មតាអាស៊ីដនេះមានកំហាប់ អ៊ីយ៉ុងអ៊ីដ្រូសែន (ប៉ូតង់ស្យែលអ៊ីដ្រូសែន – pH) រហូតដល់៣ ឬទាបជាង ។ ដូច្នេះកាកសំណល់ទាំងនេះអាចបង្កអោយខូចដល់លក្ខណៈគ្រែត្រគីមីជីវៈរបស់ដីនៅជុំវិញនោះ ប្រសិនបើគ្មានការរៀបចំប្រព័ន្ធរក្សា និងការពារកាកសំណល់រ៉ែ (Tailing Impoundment Systems) អោយបានត្រឹមត្រូវ ទេនោះ ។ | ម្ចាស់ក្រុមហ៊ុន | ១២០០០០ |

Draft

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|
| **ការទាញយករ៉ែចេញពីថ្ម និងការចោលសំណល់ (អាចម៍) រ៉ែ (ត)** | | | | |
| ការទាញយករ៉ែ និងការចោលកាកសំណល់រ៉ែ | បង្ករអោយក្រខ្វក់ដល់មជ្ឈដ្ឋានជុំវិញ ជាពិសេសតាមទឹកទំនាប | • មុនរៀបចំប្រព័ន្ធរក្សា និងការពារកាកសំណល់រ៉ែ (Tailing Impoundment Systems) ក្រុមហ៊ុនត្រូវរកទីកន្លែងអោយបានសមស្របជាមុនសិន។ កន្លែងដែលសមស្របសម្រាប់ការរៀបចំប្រព័ន្ធរក្សា និងការពារកាកសំណល់រ៉ែ ចាំបាច់ត្រូវនៅដាច់ពីគេ ធ្វើយ៉ាងណាដើម្បីបញ្ចៀសទឹកដែលជ្រាបចេញពីគំនរអាចម៍រ៉ែមិនអោយហូរចូល នឹងបំពុលដល់ទឹកស្រទាប់លើ និងទឹកក្រោមដី។<br>• ប្រព័ន្ធនេះត្រូវរៀបចំយ៉ាងណាដើម្បីកាត់បន្ថយការហូររបស់ទឹកសាប (ទឹកភ្លៀង ឬទឹកពីប្រភពផ្សេងៗទៀត) បន្ទាប់មកត្រូវធ្វើប្រព្រឹត្តកម្មទៅលើទឹកសំណល់ទាំងនោះ ដើម្បីកាត់បន្ថយកំហាប់អ៊ីយ៉ុងអ៊ីដ្រូសែន (កាត់បន្ថយការបញ្ចេញចោលមួយដែលមានជាតិពុលខ្ពស់) ទៅតាមលទ្ធភាពមួយដែលអាចធ្វើទៅបាន។<br>• ប្រព័ន្ធរក្សា និងការពារកាកសំណល់រ៉ែ ត្រូវមានលទ្ធភាពផ្ទុក និងពេលវេលាគ្រប់គ្រាន់អាចរក្សាទឹកសំណល់បាន ធ្វើដូច្នេះគឺដើម្បីធានាបានថា ទឹកដែលជ្រាបនឹងហូរចេញពីគំនរអាចម៍រ៉ែមានពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើអុកស៊ីតកម្មទៅលើអំបិលរ៉ែ (Thiosalt)។ ដោយហេតុថា តំបន់នោះមានរដូវប្រាំងតិចជាងបួនខែ ពោលគឺជាតំបន់ដែលមានភ្លៀងធ្លាក់ច្រើន ដូច្នេះនៅក្នុងដំណាក់កាលនៃការធ្វើផែនការសម្រាប់រៀបចំប្រព័ន្ធរក្សា និងការពារសំណល់រ៉ែ ក៏ត្រូវពិចារណាអំពីលទ្ធភាពរក្សាទឹកនៅពេលមានភ្លៀងផងដែរ (Buffer Capacity for the Rainy Season)។ ហើយម្យ៉ាងទៀតត្រូវរៀបប្រឡាយសម្រាប់ការហូររបស់ទឹក (Surface Runoff) ចេញពីប្រព័ន្ធនេះអោយបានត្រឹមត្រូវ។ | ម្ចាស់ក្រុមហ៊ុន | - |

Draft

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|
| **ការបិទរណ្តៅរ៉ែ និងការដាំឈើឡើងវិញ** | | | | |
| ការលប់ឬបិទប្រព័ន្ធធ្វើអោយទឹករង ប្រព័ន្ធរក្សានិងការពារកាកសំណល់ឬអាចម៍រ៉ែ | ដីគ្មានលទ្ធភាពអាចគាំទ្រដល់ដំណើរការជីវៈ បង្ករភាពក្រខ្វក់ (ពុល) ដល់មជ្ឈដ្ឋានជុំវិញ និងប្រព័ន្ធស៊ីង ខូចវិការដើម្បីជួសជុលបរិស្ថានឡើងវិញ | • នៅពេលបញ្ចប់ផែនការអាជីវកម្មនៅតាមរណ្តៅនិមួយៗ ចាំបាច់ត្រូវលុបប្រព័ន្ធធ្វើអោយទឹករងអោយបានត្រឹមត្រូវ ។ ដំណើរការលប់រណ្តៅត្រូវធ្វើយ៉ាងណាដើម្បី:<br>(១) ធ្វើអោយដីត្រឡប់ទៅរកស្ថានភាពមួយ ដែលមានលទ្ធភាពអាចគាំទ្រដល់ដំណើរការជីវៈមុនពេលមានការប្រើប្រាស់ដី ឬក៏អាចទទួលយកបានតាមលក្ខណៈផ្សេងទៀត ។<br>(២) ធ្វើយ៉ាងណាមិនឱ្យមានហេតុប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរដល់ប្រភពទឹកនៅក្បែរៗ នោះ ។<br>(៣) ត្រូវប្រើសំណល់ដុំថ្មលប់រណ្តៅជាមុន បន្ទាប់មកត្រូវប្រើដីស្រទាប់លើ (វត្ថុឬសម្ភារៈផ្សេងទៀត) ដើម្បីកែប្រែដីនោះឡើងវិញទៅតាមលទ្ធភាពមួយដែលអាចទៅបាន ។<br>(៤) ឈូសឆាយដី ឬពង្រាបដីអោយបានរាបស្មើ (កុំអោយទេរឬចោទ) ធ្វើយ៉ាងនេះដើម្បីកាត់បន្ថយការហូរច្រោះ និងការហូរនាំយកទៅនូវដីស្រទាប់លើ ។<br>(៥) ធ្វើការដាំដុះដើមឈើឡើងវិញនូវពូជឈើក្នុងស្រុក ឬពូជឈើផ្សេងៗទៀត ដែលអាចទទួលយកបានតាមលក្ខណៈបរិស្ថាន ដើម្បីធ្វើទប់ស្កាត់ការហូរច្រោះនិងធ្វើយ៉ាងណា ដើម្បីធានាបាននូវស្ថេរភាពប្រព័ន្ធអេកូឡូស៊ីដែលមានលក្ខណៈផលិតភាព នៅលើដីដែលកែប្រែទាំង នោះ ។ | ម្ចាស់ក្រុមហ៊ុន | ៥០០០០០ |
| ការលប់អណ្តូងរ៉ែ | បង្កគ្រោះថ្នាក់ដល់មនុស្ស និងសត្វ | • នៅពេលបញ្ចប់ការធ្វើអាជីវកម្មរ៉ែមាសបរិវេណយករ៉ែមាស (អណ្តូងរ៉ែ) ត្រូវបិទឱ្យត្រឹមត្រូវ:<br>(១) បិទអណ្តូងដោយការធ្វើរបងរឹងមាំព័ទ្ធជុំវិញបរិវេណយករ៉ែមាស និង/ឬ<br>(២) ប្រើម៉ៃ្សា Dynamite ដាក់បំផ្ទុះរណ្តៅអោយស្រុត បន្ទាប់មកប្រើដីស្រទាប់លើទៅដាក់បំពេញរណ្តៅដែលស្រុត ហើយនឹងដាំឈើពីលើ (នេះជាវិធីល្អបំផុតសម្រាប់ការបិទអណ្តូងរ៉ែ) ។ | ម្ចាស់ក្រុមហ៊ុន | គ្មានពតិមាន |

Draft

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|
| **ហេតុប៉ះពាល់របស់ធម្មជាតិលើប្រតិបត្តិការអាជីវកម្មរ៉ែ** | | | | |
| ហេតុប៉ះពាល់របស់អាកាសធាតុលើប្រតិបត្តិការអាជីវកម្មរ៉ែ | បង្ករអោយក្រខ្វក់ដល់មជ្ឈដ្ឋានជុំវិញ ជាពិសេសប្រព័ន្ធស៊ឹង | • អាកាសធាតុអាចមានហេតុប៉ះពាល់ធ្ងន់ធ្ងរដល់ប្រតិបត្តិការអាជីវកម្មរ៉ែ (ការជីកយក ដឹកជញ្ជូន លាងសម្អាត កិនបំបែក រែង ឬការញែកយករ៉ែចេញ ការចោលកាកសំណល់រ៉ែ) ជាពិសេសគឺបញ្ហានៃការរៀបចំ ប្រព័ន្ធធ្វើអោយទឹករង (Sedimentation Systems) និងប្រព័ន្ធរក្សានិងការពារកាកសំណល់ (អាចម៍) រ៉ែ (Tailing Impoundment Systems)។ តែហេតុប៉ះពាល់នេះអាចកាត់បន្ថយបានដោយ: (១) រៀបចំប្រព័ន្ធធ្វើអោយទឹករងដោយធ្វើយ៉ាងណា ដើម្បីឆ្លើយតបជាមួយនឹងបញ្ហាលទ្ធភាពនៃការរក្សាទឹកនៅពេលមានភ្លៀង (Buffer Capacity for the Rainy Season) និងការរៀបប្រឡាយសម្រាប់ការហូររបស់ទឹក (Surface Runoff) ចេញពីប្រព័ន្ធនេះអោយបានត្រឹមត្រូវ ។<br>(២) ប្រព័ន្ធរក្សា និងការពារកាកសំណល់រ៉ែ ចាំបាច់ត្រូវនៅដាច់ពីគេហើយត្រូវបញ្ចៀសទឹកដែលជ្រាបចេញពីគំនរអាចម៍រ៉ែ មិនអោយហូរចូលនឹងបំពុលដល់ទឹកស្រទាប់លើ និងទឹកក្រោមដី។ ប្រព័ន្ធនេះត្រូវរៀបចំយ៉ាងណាដើម្បីកាត់បន្ថយការហូររបស់ទឹកសាប (ពីប្រភពផ្សេងៗទៀត) បន្ទាប់មកត្រូវធ្វើប្រព្រឹត្តកម្មទៅលើទឹកសំណល់ទាំងនោះដើម្បីកាត់បន្ថយកំហាប់អ៊ីយ៉ុងអ៊ីដ្រូសែនទៅតាមលទ្ធភាពមួយដែលអាចធ្វើទៅបាន ។ | ម្ចាស់ក្រុមហ៊ុន | - |

Draft

**១៤០.** អ្នកសម្របសម្រួលបរិស្ថានរបស់ក្រុមហ៊ុន (Local Environmental Coordinator - LEC) នឹងត្រូវតាមដានត្រួតពិនិត្យនូវហេតុប៉ះពាល់ ដូចមានបង្ហាញជូនក្នុងតារាង ៧-១ នៅក្នុងអាយុកាលនៃប្រតិបត្តិការអាជីវកម្មរ៉ែ ដើម្បីធានាបានថាដំណើរប្រតិបត្តិនេះបានអនុវត្តន៏ទៅតាមលក្ខ័ខណ្ឌរបស់ផែនការគ្រប់គ្រងបរិស្ថាន។ ម្ចាស់គំរោងមិនត្រូវចាប់ផ្តើមដំណើរការគំរោង មុនពេលដែលក្រសួងបរិស្ថានផ្តល់ការអនុម័តជាផ្លូវការអោយដំណើរការគំរោងនោះទេ។

**១៤១.** ការតាមដានត្រួតពិនិត្យវាយតំលៃគំរោង ត្រូវធ្វើទៅតាមតម្រូវការនៃការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានដូចបានសង្ខេបនៅក្នុងតារាង ៧-៣។ ម្ចាស់គំរោង (LEC) ត្រូវធ្វើសាវនកម្មផ្ទៃក្នុងរៀងរាល់១ខែម្តងទៅលើការអនុវត្តន៏ EMP លើដំណើរការអាជីវកម្មទាំងមូល ក្នុងពេលដែលស្ថាប័នជំនាញ (មន្ត្រីក្រសួងបរិស្ថាន ឧស្សាហកម្ម រ៉ែ និងថាមពល មន្ត្រីសមត្ថកិច្ចស្រុក ខេត្ត) ត្រូវធ្វើសាវនកម្មទៅ លើការអនុវត្តន៏ EMP លើដំណើរការរបស់ប្រព័ន្ធទាំងមូលរៀងរាល់០៣ខែម្តង ដើម្បីកំណត់អំពីកំហុសឆ្គងណាមួយ និងផ្តល់សេចក្តីកែតម្រូវតាមការចាំបាច់។ ស្ថាប័នជំនាញក៏មានតួនាទីទទួលខុសត្រូវក្នុងការពិនិត្យលើនីតិវិធីប្តឹងតវ៉ា ដើម្បីធានាបានថា ការផ្តល់ប្រាក់ឧបត្ថម្ភចំពោះបុគ្គលិក/កម្មករដែលរងគ្រោះ ទទួលបានការដោះស្រាយត្រឹមត្រូវពីម្ចាស់ក្រុមហ៊ុនឬមួយយ៉ាងណា?។

**១៤២.** ម្ចាស់ក្រុមហ៊ុនត្រូវជួលជំនាញបរិស្ថាន ដើម្បីផ្តល់ការបណ្តុះបណ្តាលអំពីបទដ្ឋាននៃការគ្រប់គ្រងបរិស្ថាន គោលនយោបាយ ផែនការ និងនីតិវិធីនៃការអនុវត្តន៏ និងការត្រួតពិនិត្យតាមដានប្រព័ន្ធធ្វើប្រព្រឹត្តកម្ម ដល់បុគ្គលិករបស់ខ្លួន។ ជំនាញបរិស្ថានត្រូវរៀបចំសៀវភៅប្រតិបត្តិសង្ខេបដល់អ្នកសម្របសម្រួបបរិស្ថានរបស់ក្រុមហ៊ុន។ លើសពីនេះទៀតអ្នកសំរបសំរួលបរិស្ថានត្រូវត្រួតពិនិត្យវាយតំលៃ ហើយផ្តល់នូវមតិយោបល់ផ្សេងៗដល់ម្ចាស់ក្រុមហ៊ុន ថាតើអ្នកបច្ចេកទេសបរិស្ថានរបស់ក្រុមហ៊ុន គួរមានសមត្ថភាពកំរិតណាដើម្បីធានាបានដល់ការអនុវត្តន៏ និងការគ្រប់គ្រងការងារទាំងអស់នោះ។

## តារាង ៧-៣: សង្ខេបអំពីតំរូវការនៃការត្រួតពិនិត្យការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន

| ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ចំនួននៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **ដំណាក់កាលស្រាវជ្រាវរុករករ៉ែ - ការធ្វើផែនការ** | | | | | | |
| • ការឈូសបកដីស្រទាប់លេការរក្សា និងគ្រប់គ្រងអាចម៍ដីនេះអោយបានត្រឹមត្រូវសម្រាប់ប្រើនៅពេលបិទរណ្តៅរ៉ែ ។<br>• រៀបចំទីស្នាក់ការ ផ្ទះសម្រាប់បុគ្គលិកកម្មករស្នាក់នៅរោងជាង សួនច្បារ និងទីលានកីឡា ។<br>• កំណត់ទីតាំងសម្រាប់រក្សា និងការពារកាកសំណល់រ៉ែ ជាពិសេស ប្រសិនបើកាកសំណល់ទាំងនោះមានសារធាតុ Sulfur ដែលអាចធ្វើអោយមានជា AMD បាន ។<br>• ប្រព័ន្ធស្រះដើម្បីធ្វើទឹកអោយរង និងលទ្ធភាពរក្សាទឹកនៅពេលមានភ្លៀង ។<br>• វិធីសាស្រ្តយករ៉ែធ្វើយ៉ាងណាដើម្បីបង្កលក្ខណៈងាយស្រួលដល់ការបិទរណ្តៅ ។<br>• វិធីសាស្រ្តសម្រាប់ធ្វើការបិទរណ្តៅ និងការជួសជុលបរិស្ថានឡើងវិញ (ការកែប្រែដី និងការដាំឈើ) ។<br>• វិធីសាស្រ្តដាក់ម៉ៀផ្ទុះដែលអាចកាត់បន្ថយសម្លេង និងរំញ័រ ។ | បទដ្ឋានសម្រាប់ការរៀបចំផែនការស្រាវជ្រាវ និងធ្វើអាជីវកម្មរ៉ែ | ការិយាល័យ | ការរៀបចំផែនការបានធ្វើទៅតាមបទដ្ឋាន នៃដំណើរការធ្វើអាជីវកម្មរ៉ែ | មុនពេលដំណើរការស្រាវជ្រាវ | ម្ចាស់គំរោង | ៣៥០០០ |

| ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ចំនួននៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **ដំណាក់កាលស្រាវជ្រាវរុករករ៉ែ – ការរៀបចំផែនការសុខភាព និងសុវត្ថិភាពការងារ** | | | | | | |
| • សំអាតកន្លែងដែលមូសរស់នៅ (ទាំងក្នុងលក្ខខ័ណ្ឌធម្មជាតិ និងសិប្បនិម្មិត) ជាកន្លែងដែលមានទឹក បង្កលក្ខណៈសមស្របដល់ការបង្កាត់ពូជមូសដែលមាននៅជុំវិញនោះ ។<br>• អប់រំកម្មករ និងសហគមន៍មូលដ្ឋាន អោយបំផ្លាញទីកន្លែងជំរករបស់មូស ។<br>• ធ្វើការអង្កេត និងកំណត់អំពីដង់ស៊ីតេរបស់មូសដែលចំលងមេរោគ ។<br>• បាញ់ថ្នាំសំលាប់មូសជាប្រចាំ ជាពិសេសនៅពេលដែលមានមូសច្រើន ។ | វិធីសាស្ត្រការពារជំងឺគ្រុនឈាម | ការិយាល័យ | មានការរៀបចំវិធីសាស្ត្រការពារបានត្រឹមត្រូវល្អ និងការអនុវត្តន៍បានត្រឹមត្រូវទៅតាមវិធីសាស្ត្រនានាដែលរៀបចំឡើង | ម្តងមុនចាប់ផ្តើម និងរៀងរាល់ត្រីមាសនៅក្នុងអាយុកាលនៃការស្រាវជ្រាវ និងធ្វើអាជីវកម្មរ៉ែនេះ | ម្ចាស់ក្រុមហ៊ុន | ១២០០ |
| • ត្រូវបំបែកអ្នកជំងឺអោយនៅកន្លែងផ្សេង និងផ្តល់ការព្យាបាលជាពិសេសទៅតាមយថាប្រភេទនៃជំងឺ ។<br>• បាញ់ថ្នាំក្នុងបរិវេណរស់នៅចំងាយ២០០ម ដើម្បីសម្លាប់មូសពេញវ័យ ។<br>• ស្វែងរក និងបំផ្លាញទីតាំងជម្រកមូស ។<br>• ចាំបាច់ត្រូវប្រើថ្នាំសំលាប់ពងមូសចំពោះទីកន្លែងដែលមានមូសច្រើន ។<br>• អប់រំដល់បុគ្គលិកកម្មករ និងសហគមន៍អំពីវិធានការណ៍គ្រប់គ្រងការរាគត្បាត ។ | វិធានការណ៍ការគ្រប់គ្រងការរាគត្បាត | ការិយាល័យ | មានការរៀបចំវិធីសាស្ត្រការពារបានត្រឹមត្រូវល្អ និងការអនុវត្តន៍បានត្រឹមត្រូវទៅតាមវិធីសាស្ត្រនានាដែលរៀបចំឡើង | ម្តងមុនចាប់ផ្តើម និងរៀងរាល់ត្រីមាសនៅក្នុងអាយុកាលនៃការស្រាវជ្រាវ និងធ្វើអាជីវកម្មរ៉ែនេះ | ម្ចាស់ក្រុមហ៊ុន | - |

Draft

| ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ចំនួននៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **ដំណាក់កាលស្រាវជ្រាវរុករករ៉ែ - ការរៀបចំផែនការសុខភាព និងសុវត្ថិភាពការងារ** | | | | | | |
| • ក្រុមហ៊ុនត្រូវផ្តល់ទឹកស្អាតដល់កម្មករ ។ បច្ចុប្បន្នក្រុមហ៊ុនបានជីកស្រះត្រងទឹកស្រទាប់លើ បន្ទាប់ពីច្រោះទឹកនេះអោយស្អាតហើយ យកទៅដាំអោយពុះទើបប្រើប្រាស់ ។<br>• ត្រួតពិនិត្យជាប្រចាំ អំពីគុណភាពរបស់ទឹក (វត្តមានរបស់បាក់តេរី សារធាតុគីមី និងពណ៌របស់ទឹក)<br>• ត្រូវធ្វើ រោគវិនិច្ឆ័យនិងផ្តល់ការព្យាបាលអោយបានគ្រប់គ្រាន់និងទាន់ពេលវេលា ។<br>• តាមដានរក ប្រភពចំលង និងផ្តល់ការព្យាបាល ។<br>• ធានាអោយបាននូវសុវត្ថិភាព និងសម្អាតសម្រាម និងការបោះចោលនូវកាកសំណល់រឹងនៅក្នុងផ្ទះដែលសង់សំរាប់កម្មករ ។<br>• កែលំអការសម្អាត បរិស្ថាននៅក្នុងបរិវេណទីស្នាក់ការ និងទីកន្លែងរស់នៅ ដោយការសង់បង្គន់អនាម័យ និងកន្លែងសំរាប់ចោលកាកសំណល់រឹង ។<br>• កែលំអអនាម័យបុគ្គល ជាពិសេសចំពោះអ្នករៀបចំអាហារ ។<br>• ផ្តល់វ៉ាក់សាំងចំពោះបុគ្គលិក ឬកម្មករបរទេសដែលពុំមានអង់ទីករប្រឆាំងជំងឺគ្រុនពោះវៀន អាសន្នរោគ និងរលាកថ្លើម ។<br>• រាយការណ៍និងធ្វើការត្រួតពិនិត្យអំពីឧប្បត្តិហេតុ របស់ជំងឺ ។ | វិធានការណ៍ការពារជំងឺដែលបង្កឡើងដោយការប្រើប្រាស់ទឹកមិនស្អាត | ការិយាល័យ | មានការរៀបចំវិធីសាស្ត្រការពារបានត្រឹមត្រូវល្អ នឹងការអនុវត្តន៍បានត្រឹមត្រូវទៅតាមវិធីសាស្ត្រនានាដែលរៀបចំឡើង | ម្តងមុនចាប់ផ្តើម និងរៀងរាល់ត្រីមាសនៅក្នុងអាយុកាលនៃការស្រាវជ្រាវ និងធ្វើអាជីវកម្មរ៉ែនេះ | ម្ចាស់ក្រុមហ៊ុន | ៣៥០០ |

| ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ចំនួននៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **ដំណាក់កាលស្រាវជ្រាវរុករករ៉ែ – ការរៀបចំផែនការសុខភាព និងសុវត្ថិភាពការងារ** | | | | | | |
| • អប់រំបុគ្គលិក កម្មករអំពីគ្រោះថ្នាក់នៃការឆ្លងជំងឺអេដស៍ និងជំងឺផ្លូវភេទផ្សេងៗទៀត ដូចជាការទប់ស្កាត់នូវទំនាក់ទំនងជាមួយអ្នកដែលធ្វើអាជីវកម្មលើផ្លូវភេទ ការប្រើប្រាស់ស្រោមអនាម័យ ណែនាំអ្នកជំងឺអោយព្យាបាលជាមួយនឹងគ្រូពេទ្យដែលមាន បទពិសោធន៍ និងមិនត្រូវព្យាបាលដោយខ្លួនឯង ។<br>• រាយការណ៍អំពីអ្នកជំងឺ ស្វែងរកអ្នកចំលងនិងត្រួតពិនិត្យករណីនៃការកើតមានរបស់ជំងឺ ដោយការិយាល័យសុខាភិបាលនៅក្នុងតំបន់ ។ ប្រសិទ្ធិភាពនៃកម្មវិធីការពារជំងឺផ្លូវភេទទាមទារឱ្យមានកិច្ចសហប្រតិបត្តិការ រវាងអាជ្ញាសុខាភិបាល អាជ្ញាធរ និងសហគមន៍មូលដ្ឋាន និងក្រុមហ៊ុន ។ | វិធានការណ៍ ការពារជំងឺផ្លូវភេទ | ការិយាល័យ | មានការរៀបចំវិធីសាស្រ្តការពារបានត្រឹមត្រូវល្អ និងការអនុវត្តន៍បានត្រឹមត្រូវទៅតាមវិធីសាស្រ្តនានាដែលរៀបចំឡើង | ម្តងមុនចាប់ផ្តើម និងរៀងរាល់ត្រីមាស នៅក្នុងអាយុកាលនៃការស្រាវជ្រាវ និងធ្វើអាជីវកម្មរ៉ែនេះ | ម្ចាស់ក្រុមហ៊ុន | ៣៥០០ |

| ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ចំនួននៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **ដំណាក់កាលស្រាវជ្រាវរុករករ៉ែ - ការរៀបចំផែនការសុខភាព និងសុវត្ថិភាពការងារ** | | | | | | |
| • ក្រុមហ៊ុនត្រូវរៀបចំប្លង់កសាងទីស្នាក់ស្នូលអោយបានត្រឹមត្រូវ<br>• ត្រូវផ្តល់ផ្ទះដល់កម្មករទៅតាមលក្ខខ័ណ្ឌ:<br>• លក្ខណៈរូប: ទីតាំងផ្ទះ ចាំបាច់ត្រូវស្ថិតនៅផុតពីកំពស់ទឹកជំនន់ ស្ថិតនៅឆ្ងាយពីទីកន្លែងដែលអាចផ្តល់ភាពក្រខ្វក់និងកន្លែងដែលមានសត្វល្អិតច្រើន ។ ផ្ទះកម្មករត្រូវមានសំណាញ់ការពារមូស និងមានឆ្នាំការពារចោរ ហើយត្រូវមានពន្លឺគ្រប់គ្រាន់ ។ ម៉្យាងវិញទៀត ទីតាំងរបស់ផ្ទះនិងបន្ទប់ត្រូវមានចរន្តខ្យល់គ្រប់គ្រាន់ (ផ្ទៃបន្ទប់ត្រូវបើកចំហយ៉ាងតិច១០ភាគរយ) ។<br>• លក្ខណៈអនាម័យ: ផ្តល់ទឹកស្អាតអោយបានគ្រប់គ្រាន់ ជាមួយនឹងមធ្យោបាយសំរាប់ដុសលាង និងងូតទឹក។ សង់បង្គន់អនាម័យ និងកន្លែងសំរាប់ចោលកាកសំណល់រឹងត្រឹមត្រូវ<br>• ពិនិត្យអំពីលទ្ធភាពនៃការផ្តល់កន្លែងសំរាប់លំហែ (តារាងបាល់បោះ បាល់ទះ និងបាល់ទាត់) និងមណ្ឌលសុខភាព ។ | មានសមាហរ័ណកម្មបរិស្ថាន និងសុខភាព | ការិយាល័យ | មានការរៀបចំត្រឹមត្រូវទៅតាមគោលការណ៍សមាហរ័ណកម្មបរិស្ថាន និងសុខភាព | ម្តងមុនចាប់ផ្តើម និងរៀងរាល់ត្រីមាស នៅក្នុងអាយុកាលនៃការស្រាវជ្រាវ និងធ្វើអាជីវកម្មរ៉ែនេះ | ម្ចាស់ក្រុមហ៊ុន | ១២០០០០ |

Draft

| ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ចំនួននៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **ដំណាក់កាលស្រាវជ្រាវរុករករ៉ែ – ការរៀបចំផែនការសុខភាព និងសុវត្ថិភាពការងារ** | | | | | | |
| • រៀបចំ និងអនុវត្តនូវគោលការណ៍សុវត្ថិភាពទៅតាមបទដ្ឋានការងារក្នុងអណ្តូងរ៉ែ<br>• បំពាក់មួកការពារអោយដល់គ្រប់កម្មករ ដែលធ្វើការក្នុងអណ្តូងរ៉ែ ដើម្បីការពារក្បាលពីការធ្លាក់ថ្មដោយចៃដន្យ<br>• ផ្តល់មធ្យោបាយសំរាប់ព្យាបាល បន្ទាន់នៅក្នុងគ្លីនីករបស់ទីស្នាក់ការស្ទួល<br>• រៀបចំវិធានការណ៍សំរាប់សង្គ្រោះបន្ទាន់ ដើម្បីបញ្ជូនអ្នករងគ្រោះឬអ្នកជំងឺធ្ងន់ធ្ងរទៅកាន់មន្ទីរពេទ្យ ។ | កំនើននៃគ្រោះថ្នាក់ក្នុងពេលធ្វើការ និងការធ្វើចរាចរ | ការិយាល័យ | មានការរៀបចំវិធីសាស្ត្រការពារបានត្រឹមត្រូវល្អ នឹងការអនុវត្តន៍បានត្រឹមត្រូវទៅតាមវិធីសាស្ត្រនានាដែលរៀបចំឡើង | ម្តងមុនចាប់ផ្តើម និងរៀងរាល់ត្រីមាស នៅក្នុងអាយុកាលនៃការស្រាវជ្រាវ និងធ្វើអាជីវកម្មរ៉ែ | ម្ចាស់ក្រុមហ៊ុន | ២០០០ |
| • ការរៀបចំផែនការសុខភាព និងសុវត្ថិភាពការងារ ការផ្តល់នូវការបណ្តុះបណ្តាលផ្សេងៗ និងការណែនាំដល់បុគ្គលិកកម្មករទាំងមុនពេលប្រគល់ភារកិច្ចផ្សេងៗ ។ | សុខភាពការងារ និងផែនការសុវត្ថិភាព | ការិយាល័យ | បុគ្គលិកទាំងអស់ទទួលបានការបណ្តុះបណ្តាលពេញលេញ | ម្តងមុនចាប់ផ្តើម និងរៀងរាល់ត្រីមាស នៅក្នុងអាយុកាលនៃការស្រាវជ្រាវ និងធ្វើអាជីវកម្មរ៉ែ | អ្នកម៉ៅការរៀបចំប្លង់និងសាងសង់ | ២៥០០ |

Draft

| ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ចំនួននៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **ដំណាក់កាលស្រាវជ្រាវរុករករ៉ែ - ការសាងសង់ទីស្នាក់ការទេ និងរោងចក្រកិនរ៉ែ** | | | | | | |
| • កាកសំណល់ឈើធំៗ (គល់ សំបក ដើម និងមែក) ដែលកើតមាននៅក្នុងរយៈពេលនៃការសាងសង់ត្រូវកាត់ទៅជាកំណាត់តូចៗ ហើយឈូសទៅគរនៅកន្លែងមួយសមស្រប (មិនត្រូវរុញអោយទៅកកស្ទះនឹងរុក្ខជាតិក្បែរៗនោះ ឬក៏នៅកន្លែងទីជំរាលនោះទេ។ ពីព្រោះថាក្រៅពីអាចប្រើប្រាស់ជាឧសដុត វាអាចជួយការពារដី ហើយម្យ៉ាងទៀតក្រោយពេលពុកផុយវានឹងផ្តល់ជីដល់ដីទៀតផង។<br>• ត្រូវជ្រើសរើសកន្លែងគរឈើដោយប្រុងប្រយ័ត្ន ដើម្បីចៀសវាងកន្លែងដែលមានដំណុះរុក្ខជាតិក្រាស់ និងក្បែរផ្លូវទឹក។ ការហូរច្រោះផ្ទៃខាងលើរបស់ដីកើតមានឡើងតិចតួច ចំពោះកន្លែងណាដែលសណ្ឋានដីមានលក្ខណៈរាបស្មើ។ នៅជុំវិញកន្លែងគរឈើចាំបាច់ត្រូវមានតំបន់ក្រវ៉ាត់ដែលមានដុះរុក្ខជាតិក្រាស់ ដើម្បីទប់ស្កាត់ការហូរជ័រ និងសារធាតុពុលផ្សេងៗទៀតចេញពីឈើ នៅពេលដែលមានភ្លៀងធ្លាក់ខ្លាំង ជ័រនិងកាកសំណល់ផ្សេងៗទៀតដែលកើតមានឡើង នៅពេលកាប់ឈើចាំបាច់ត្រូវយកចេញ និងចោលឱ្យបានត្រឹមត្រូវ។<br>• ក្រោយពេលសាងសង់រួច (ទីស្នាក់ការស្នូល ផ្ទះបុគ្គលិក កម្មករ ផ្ទះបាយ រោងជាងបង្គន់អនាម័យ ផ្លូវនៅក្នុងបរិវេណ ទីធ្លាកីឡា...) ផ្ទៃដីដែលនៅសេសសល់ត្រូវរៀបចំដាំឈើឡើងវិញជាបន្ទាន់ ដោយមានការរៀបចំអោយទៅជាលក្ខណៈសួនច្បារ ឬច្បារដំណាំ (ពពួកបន្លែជាដើម) ធ្វើដូច្នេះគឺដើម្បីកាត់បន្ថយការហូរច្រោះដីពីទីកន្លែងនោះ។ | *បង្ការការក្រខ្វក់ដល់បរិស្ថានជុំវិញដោយការឈូសសម្អាតតំបន់ព្រៃ* | ការិយាល័យ | អនុវត្តន៍បានត្រឹមត្រូវទៅតាមវិធានការណ៍នានាដែលបានកំណត់ | បីដង (ម្តងមុនចាប់ផ្តើម ម្តងក្នុងពេលសាងសង់ និង ម្តងក្រោយពេលសង់រួច | ម្ចាស់ក្រុមហ៊ុន | ២០០០ |

| ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ចំនួននៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **ដំណាក់កាលស្រាវជ្រាវរុករករ៉ែ – ការសាងសង់ផ្លូវទៅកាន់អណ្តូងស្រាវជ្រាវរ៉ែ** | | | | | | |
| • កាកសំណល់ឈើធំៗត្រូវកាត់ទៅជាកំណាត់តូចៗ និងរាយនៅតាមដងផ្លូវ។ មិនត្រូវរុញអោយទៅកកស្ទះនឹងរុក្ខជាតិនៅតាមដងផ្លូវ និងទីជំរាលនេះទេ។ ពីព្រោះថាក្រៅពីការការពារដីកាកសំណល់នេះនឹងពុកផុយហើយនឹងផ្តល់ជី ដល់ដីទៀតផង។<br>• ការកំណត់នូវកន្លែងសំរាប់ដាក់លូមានសារៈសំខាន់ណាស់ ពីព្រោះការរំដោះទឹកចេញពីផ្នែកម្ខាង ទៅផ្នែកម្ខាងទៀតចាំបាច់ត្រូវធ្លាក់ទៅលើកន្លែងដែលមានដីរឹង។<br>• រក្សានូវមុំរបស់ផ្លូវទៅតាមលក្ខណៈវិស្វកម្មរបស់ផ្លូវ (មិនធំជាង១០ភាគរយ ចំពោះដីជ្រាយ និងមិនធំជាង១៤ភាគរយ ចំពោះដីរឹង)។<br>• ត្រូវកាយចង្អូរនៅតាមដងផ្លូវ ហើយទ្រូងផ្លូវត្រូវមានរាងជាខ្នងអណ្តើក ដើម្បីឱ្យងាយហូរធ្លាក់ទៅចង្អូរ។<br>• ចៀសវាងការឈូសឆាយតំបន់ព្រៃនៅក្នុងពេលកំពុងភ្លៀង ឬពេលដីសើមខ្លាំង។<br>• ខ្នងផ្លូវត្រូវក្រាលថ្មបាយក្រៀម ឬក៏កំទេចថ្ម។<br>• ប្រើគ្រឿងចក្រអោយបានសមស្របដើម្បីកាត់បន្ថយហេតុប៉ះពាល់ពីការដាច់ដី។<br>• ការដាក់លូអោយបានសមស្របតាមទីកន្លែង អាចនឹងកាត់បន្ថយនូវការប៉ះពាល់ទូទៅដល់សត្វដែលរស់នៅក្នុងទឹក។<br>• ដើម្បីកាត់បន្ថយនូវការដែលអាចបង្កអោយមានភាពក្រខ្វក់ដល់ផ្លូវទឹក ការសាងសង់ផ្លូវទៅកាន់អណ្តូងរ៉ែ ត្រូវធ្វើនៅក្នុងរដូវប្រាំង។<br>• ការពារតំបន់រណបរបស់អូរ និងស្ទឹង។ | *បង្ករការក្រខ្វក់ដល់មជ្ឈដ្ឋានជុំវិញដោយការឈូសសម្អាតតំបន់រុក្ខជាតិ ដែលដុះអមតាមសងខាងផ្លូវ* | ការិយាល័យ | អនុវត្តន៍បានត្រឹមត្រូវទៅតាមវិធានការណ៍នានាដែលបានកំណត់ | បីដង (ម្តងមុនចាប់ផ្តើម ម្តងក្នុងពេលសាងសង់ និងម្តងក្រោយពេលសង់រួច | ម្ចាស់ក្រុមហ៊ុន | - |

| ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ចំនួននៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **ការជីកយករ៉ែ និងដឹកជញ្ជូនរ៉ែទៅកាន់រោងចក្រ - ការដឹកជញ្ជូន** | | | | | | |
| • ការក្រាលផ្លូវដោយគ្រួសក្រហម និងធ្វើការជ្រើមផ្លូវដោយការស្រោចទឹកជាប្រចាំ។ | ក្រាលគ្រួស និងការជ្រើមផ្លូវជាប្រចាំ | ទីវាល | អនុវត្តន៍បានត្រឹមត្រូវតាមវិធានការណ៍កំណត់ | រៀងរាល់៦ខែម្តង | ម្ចាស់ក្រុមហ៊ុន | ១២០០ |
| **ការទាញយករ៉ែចេញពីថ្ម និងការចោលសំណល់ (អាចម៍) រ៉ែ - ការលាងសម្អាតរ៉ែ** | | | | | | |
| • រៀបចំប្រព័ន្ធស្រះ (Sedimentation Systems) អោយត្រូវទៅតាមបទដ្ឋានបច្ចេកទេស សម្រាប់ការធ្វើអាជីវកម្មលើរ៉ែ។ ប្រព័ន្ធនេះត្រូវមានលទ្ធភាពរក្សាទឹក (ទាំងបរិមាណនិងពេលវេលាសម្រាប់បង្ហាំងទឹក) សំណល់ទាំងនោះអោយរងបានល្អជាមុន (ឬមានពេលវេលាគ្រប់គ្រាន់សម្រាប់ការធ្វើអុកស៊ីតកម្ម ទៅលើប្រភេទអំបិលរ៉ែមួយចំនួនដូចជា Thiosalt ជាដើម) មុននឹងបញ្ចេញចោល។<br>• នៅរដូវវស្សាមានភ្លៀងធ្លាក់ច្រើន ដូច្នេះនៅក្នុងដំណាក់កាលនៃការធ្វើផែនការសម្រាប់រៀបចំប្រព័ន្ធ Sedimentation ក៏ត្រូវពិចារណាអំពីលទ្ធភាពរក្សាទឹកនៅពេលមានភ្លៀងផងដែរ (Buffer Capacity for the Rainy Season)។ | ការធ្វើក្រខ្វក់ដល់មជ្ឈដ្ឋានជុំវិញ ជាពិសេស ទីទំនាប | ទីវាល | អនុវត្តន៍បានត្រឹមត្រូវទៅតាមវិធានការណ៍នានាដែលបានកំណត់ | ១ខែ ម្តង | ម្ចាស់ក្រុមហ៊ុន ក្រសួងបរិស្ថាន ស្ថាប័ន/បុគ្គលត្រួតពិនិត្យឯករាជ្យ | ១៥០០០០ |
| **ការទាញយករ៉ែចេញពីថ្ម និងការចោលសំណល់ (អាចម៍) រ៉ែ - ការកិនបំបែករ៉ែ** | | | | | | |
| • ត្រូវបំពាក់ឧបករណ៍ការពារត្រចៀក អោយដល់បុគ្គលិកកម្មដែលធ្វើការនៅកន្លែងកិនថ្ម។<br>• ប្រើគំរបឬផ្ទាំងអ្វីមួយទៅហ៊ុំព័ទ្ធបរិវេណកិនបំបែកថ្មដើម្បីទប់ស្កាត់ (កាត់បន្ថយ) ការបំភាយធូលីចេញ។ | កំរិតសម្លេង និងឧបករណ៍ការពារត្រចៀក | រោងចក្រកិនថ្ម | អនុវត្តន៍បានត្រឹមត្រូវទៅតាមវិធានការណ៍នានាដែលបានកំណត់ | ១ខែ ម្តង | ម្ចាស់ក្រុមហ៊ុន ស្ថាប័ន/បុគ្គលត្រួតពិនិត្យឯករាជ្យ | ១២០០ |

Draft

| ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ចំនួននៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **ការទាញយករ៉ែ និងការចោលកាកសំណល់រ៉ែ** | | | | | | |
| • កាកសំណល់រ៉ែទាំងនោះត្រូវដឹកយកទៅរក្សាទុកនៅកន្លែងរាបស្មើ ហើយនៅឆ្ងាយពីប្រព័ន្ធស្ទឹង។ កាកសំណល់ទាំងនេះត្រូវទុកប្រើសម្រាប់បិទរណ្តៅរ៉ែ។<br>• រកកន្លែងរៀបចំប្រព័ន្ធរក្សា និងការពារកាកសំណល់រ៉ែ (Tailing Impoundment Systems)។ កន្លែងដែលសមស្របសម្រាប់ការរៀបចំប្រព័ន្ធរក្សា និងការពារកាកសំណល់រ៉ែចាំបាច់ត្រូវនៅដាច់ពីគេ ធ្វើយ៉ាងណាដើម្បីបញ្ចៀសទឹកដែលជ្រាបចេញពីគំនរអាចម៍រ៉ែមិនអោយហូរចូល នឹងបំពុលដល់ទឹកស្រទាប់លើ និងទឹកក្រោមដី។<br>• ប្រព័ន្ធនេះត្រូវរៀបចំយ៉ាងណាដើម្បីកាត់បន្ថយការហូររបស់ទឹកសាប (ទឹកភ្លៀង ឬទឹកពីប្រភពផ្សេងៗទៀត) បន្ទាប់មកត្រូវធ្វើប្រព្រឹត្តកម្មទៅលើទឹកសំណល់ទាំងនោះ ដើម្បីកាត់បន្ថយកំហាប់អ៊ីយ៉ុងអ៊ីដ្រូសែន (កាត់បន្ថយការបញ្ចេញចោលមួយដែលមានជាតិពុលខ្ពស់) ទៅតាមលទ្ធភាពមួយដែលអាចធ្វើទៅបាន។<br>• ប្រព័ន្ធរក្សានិងការពារកាកសំណល់ត្រូវមានលទ្ធភាពផ្ទុក និងពេលវេលាគ្រប់គ្រាន់អាចរក្សាទឹកសំណល់បាន ដើម្បីធានាបានថាទឹកដែលជ្រាបនឹងហូរចេញពីគំនរអាចម៍រ៉ែ មានពេលវេលាធ្វើអុកស៊ីតកម្មទៅលើអំបិលរ៉ែ (Thiosalt)។ ដោយតំបន់នោះមានរដូវប្រាំងតិចជាងបួនខែ ដូច្នេះពេលធ្វើផែនការសម្រាប់រៀបចំប្រព័ន្ធរក្សា និងការពារសំណល់រ៉ែត្រូវពិចារណាពីលទ្ធភាពរក្សាទឹកនៅពេលមានភ្លៀងផងដែរ (Buffer Capacity for the Rainy Season)។ ហើយត្រូវរៀបប្រឡាយសម្រាប់ការហូរទឹក (Surface Runoff) ចេញពីប្រព័ន្ធនេះអោយបានត្រឹមត្រូវ។ | បទដ្ឋានប្រព័ន្ធរក្សា និងការពារកាកសំណល់ និងការធ្វើក្រខ្វក់ដល់មជ្ឈដ្ឋានជុំវិញ ជាពិសេសតាមទីទំនាប | ទីវាល | អនុវត្តន៍បានត្រឹមត្រូវ ទៅតាមវិធានការណ៍នានាដែលបានកំណត់ | ១ខែ ម្តង | ម្ចាស់ក្រុមហ៊ុន<br>ក្រសួងបរិស្ថាន<br>ស្ថាប័ន/បុគ្គលត្រួតពិនិត្យឯករាជ្យ | ១២០០០០ |

Draft

| ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ចំនួននៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **ការបិទរណ្តៅរ៉ែ និងការដាំឈើឡើងវិញ - ការលប់ឬបិទប្រព័ន្ធធ្វើអោយ ទឹករង ប្រព័ន្ធរក្សានិងការពារ កាកសំណល់ឬអាចម៍រ៉ែ** | | | | | | |
| • ស្តារដីអោយមានលទ្ធភាពអាចគាំទ្រដល់ដំណើរការជីវ: មុនពេលប្រើប្រាស់ដី ឬអាចទទួលយកបានតាមលក្ខណ:ផ្សេងទៀត ។<br>• ធ្វើយ៉ាងណាមិនឱ្យមានហេតុប៉ះពាល់អវិជ្ជមានដល់ប្រភពទឹកនៅក្បែរៗ នោះ ។<br>• ត្រូវប្រើសំណល់ដុំថ្មលប់រណ្តៅជាមុន បន្ទាប់មកប្រើដីស្រទាប់លើក្នុងការស្តារដីនោះឡើងវិញទៅតាមលទ្ធភាពមួយដែលអាចទៅបាន ។<br>• ឈូសដីអោយស្មើដើម្បីកាត់បន្ថយការហូរច្រោះដីស្រទាប់លើ ។<br>• ដាំដើមឈើឡើងវិញ (ពូជក្នុងស្រុកឬពូជឈើផ្សេងៗទៀត) ដែលអាចទទួលយកបានតាមលក្ខណ:បរិស្ថាន ដើម្បីធ្វើទប់ស្កាត់ការហូរច្រោះ និងធ្វើយ៉ាងណាដើម្បីធានាបាននូវស្ថេរភាពប្រព័ន្ធអេកូឡូស៊ីដែលមានលក្ខណ:ផលិតភាព នៅលើដីដែលកែប្រែទាំងនោះ ។<br>• គ្រប់គ្រង AMD និងកាកសំណល់ ក្រោយពេលបិទរណ្តៅរ៉ែទាំងនោះហើយ ដោយការបិទអោយជិតនូវប្រភេទកាកសំណល់ដែលសារធាតុ Pyrites ធ្វើដូច្នេះគឺដើម្បីការពារសារធាតុនេះចេញពីការធ្វើអុកស៊ីតកម្ម និងការជ្រាបនូវសារធាតុទាំងនោះចូលទៅក្នុងចរន្តទឹក ។<br>• ក្រុមហ៊ុនត្រូវមានថវិកាបម្រុងគ្រប់គ្រាន់សម្រាប់ការស្តារដីឡើងវិញ ។ ថវិកាបម្រុងនេះ ត្រូវបម្រុងទុកនៅក្នុងអាយុកាលនៃការធ្វើអាជីវកម្មទៅលើរ៉ែទាំងនេះដើម្បីប្រើប្រាស់ក្នុងការលុបរណ្តៅ និងកែប្រែធម្មជាតិតំបន់នោះឡើងវិញ ។ | បទដ្ឋានការងារ និងការធ្វើក្រខ្វក់ដល់មជ្ឈដ្ឋានជុំវិញ ជាពិសេស តាមទីទំនាប | ទីវាល | អនុវត្តន៍បានត្រឹមត្រូវ ទៅតាមវិធានការណ៍នានា ដែលបានកំណត់ | ២ខែ ម្តង | ម្ចាស់ក្រុមហ៊ុន ក្រសួងបរិស្ថាន ស្ថាប័ន/បុគ្គលត្រួតពិនិត្យឯករាជ្យ | ៥០០០០ |

| ការលើកឡើងនូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ចំនួននៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **ហេតុប៉ះពាល់របស់ធម្មជាតិលើប្រតិបត្តិការអាជីវកម្មរ៉ែ** | | | | | | |
| • រៀបចំប្រព័ន្ធធ្វើអោយទឹករង ដោយធ្វើយ៉ាងណាដើម្បីឆ្លើយតបជាមួយនឹងបញ្ហាលទ្ធភាពនៃការរក្សាទឹកនៅពេលមានភ្លៀង (Buffer Capacity for the Rainy Season) និងការរៀប ប្រឡាយសម្រាប់ការហូររបស់ទឹក (Surface Runoff) ចេញពីប្រព័ន្ធនេះអោយបានត្រឹមត្រូវ ។<br>• ដោយហេតុថាតំបន់នោះមានរដូវប្រាំងតិចជាងបួនខែ ពោលគឺជាតំបន់ដែលមានភ្លៀងធ្លាក់ច្រើន ដូច្នេះនៅក្នុងដំណាក់កាលនៃការធ្វើផែនការសម្រាប់រៀបចំប្រព័ន្ធ Sedimentation ក៏ត្រូវពិចារណាអំពីលទ្ធភាពរក្សាទឹកនៅពេលមានភ្លៀងផងដែរ (Buffer Capacity for the Rainy Season) ។<br>• ប្រព័ន្ធរក្សា និងការពារកាកសំណល់រ៉ែត្រូវមានលទ្ធភាពផ្ទុក និងពេលវេលាគ្រប់គ្រាន់អាចរក្សាទឹកសំណល់បាន គឺដើម្បីធានាបានថា ទឹកដែលជ្រាបនឹងហូរចេញពីគំនរអាចម៍រ៉ែមាន ពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើអុកស៊ីតកម្មទៅលើអំបិលរ៉ែ (Thiosalt) ។ ដោយតំបន់នោះមានរដូវប្រាំងតិចជាងបួនខែ ដូច្នេះពេលធ្វើផែនការសម្រាប់រៀបចំប្រព័ន្ធរក្សា និងការពារសំណល់រ៉ែ ត្រូវពិចារណាអំពីលទ្ធភាពរក្សាទឹកនៅពេលមានភ្លៀងផងដែរ (Buffer Capacity for the Rainy Season) ។ ហើយម្យ៉ាងទៀតត្រូវរៀបប្រឡាយសម្រាប់ការហូររបស់ទឹក (Surface Runoff) ចេញពីប្រព័ន្ធនេះអោយបានត្រឹមត្រូវ ។ | បទដ្ឋានការងារ និងការធ្វើក្រខ្វក់ដល់មជ្ឈដ្ឋានជុំវិញ ជាពិសេសប្រព័ន្ធស៊ឹង | ទីវាល | អនុវត្តន៍បានត្រឹមត្រូវទៅតាមវិធានការណ៍នានាដែលបានកំណត់ | ២ខែ ម្តង | ម្ចាស់ក្រុមហ៊ុន ក្រសួងបរិស្ថាន ស្ថាប័ន/បុគ្គលត្រួតពិនិត្យឯករាជ្យ | - |